ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ
លេខៈ ៦០
ចុះថ្ងៃទី១៦-០៩-១៩៩៩
សាលដីកាលេខ៖ ៦០
ចុះថ្ងៃទី១៨-១០-២០០០

បានបើកសវនាការជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ ២០០០ ដោយ មានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចតទៅ៖

១-ឯកឧត្តម ... ប្រធាន
២-លោក ... ចៅក្រមរបាយការណ៍
៣-លោក ... ចៅក្រម
៤-លោក ... ចៅក្រម
៥-លោក ... ចៅក្រម

ក្រឡាបញ្ជី
លោក...
តំណាងមហាអយ្យការ
ឯកឧត្តម...ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជម្រះ លើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ១៦៤ ចុះថ្ងៃទី២៥-៦-១៩៩៩ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ៦០ ចុះថ្ងៃទី១៦-៩-១៩៩៩ របស់តុលាការកំពូល។

**ពីបទ:** សម្លាប់មនុស្សគិតទុកជាមុន និងប្លន់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៦-០៨-៩២ បទល្មើសដែលមានចែងតាមបញ្ញត្តិមាត្រា៣១ និង ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-ជនជាប់ចោទ ឈ្មោះ **ឃសធ** ហៅ ក្តាម ម្ចាស់បណ្តឹងសាទុក្ខ ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ កើតនៅភូមិក្រែក ស្រុកពញាក្រែក ខេត្តកំពង់ចាម មុខរបរនគរបាលព្រំដែនប្រចាំក្រុងព្រះសីហនុ មានទីលំនៅមុនពេលចាប់ខ្លួន ផ្ទះលេខ២០អឺ០ ផ្លូវលេខ២០០ សង្កាត់បឹងរាំង ខណ្ឌដូនពេញក្រុងភ្នំពេញ។ ឪពុកឈ្មោះ...ម្តាយឈ្មោះ...នៅលីវ ទោសពីមុនគ្មាន ឃុំខ្លួនកាលពីថ្ងៃទី២០-០១-១៩៩៨។

-មានមេធាវី លោក...

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ គហ (ចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ ៤៦ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅសព្វថ្ងៃ ភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង។

មេធាវីគ្មាន។

-តាមពាក្យបណ្តឹង ចុះថ្ងៃទី០៤-៩-១៩៩៦ របស់ឈ្មោះ **គហ** ជាបងស្រី និងជាអាណាព្យាបាលរបស់ជនរងគ្រោះឈ្មោះ **គបណ** ប្តឹងពីជនមិនស្គាល់មុខ និងបក្សពួក ដែលបានធ្វើឃាតមកលើប្អូនប្រុសខ្លួនឈ្មោះ **គបណ** កាលពីថ្ងៃទី០៦-០៨-១៩៩៦ នៅចន្លោះពីម៉ោង៣ ទៅម៉ោង៤ ទៀបភ្លឺនៅមុខផ្ទះលេខ ២២អឺ០ ផ្លូវលេខ ២០០ក្រុមទី៦ សង្កាត់បឹងរាំង ខណ្ឌដូនពេញ។ ខ្លួនសំណូមពរសុំទាមទារការខូចខាតអនាគតក្រុមគ្រួសារ ជាទឹកប្រាក់១០ម៉ឺនដុល្លាអាមេរិក ជំងឺចិត្ត និងប្រាក់ឧបត្ថម្ភគ្រួសារចិញ្ចឹមកូន និងចំណាយលើបុណ្យសពចំនួន៥ម៉ឺន

ដុល្លាអាមេរិក ខាតបង់ទ្រព្យសម្បត្តិគ្រឿងអលង្កា២០ពាន់ ដុល្លាអាមេរិកសរុប ១៧០ពាន់ដុល្លាអាមេរិក។

- បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមតុលាការក្រុងភ្នំពេញ ថា៖

១-ចោទប្រកាន់លើឈ្មោះ **ឃសធ** ហៅក្តាម ភេទប្រុសអាយុ២៨ឆ្នាំ ចោទពីបទសម្លាប់មនុស្សដោយគិតទុកជាមុន និងប្លន់ ប្រព្រឹត្តនៅក្នុងភ្នំពេញ កាលពីថ្ងៃទី០៦-០៨-១៩៩៦ បទល្មើស ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣១ និង៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

២-បង្គង់បណ្តឹងអាជ្ញាលើគូកន (គ្មានសាវតាជាតិ) ពីបទសម្លាប់មនុស្សដោយគិតទុកជាមុន និងប្លន់ប្រព្រឹត្ត នៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៦-៨-១៩៩៦ បទល្មើសដែលបានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣១ និង៣៤នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៧១(ខ)ចុះថ្ងៃទី០៤-១១-១៩៩៧ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារសេចក្តីសម្រេចដូចតទៅ៖

១-ផ្តន្ទាទោសឈ្មោះ **ឃសធ** (ក្តាម) ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ កើតនៅភូមិក្រែច ឃុំក្រែក ស្រុកពញាក្រែក ខេត្តកំពង់ចាម កំរិតវប្បធម៌ ជាប់មធ្យមសិក្សាកម្រិត២ សាសនាព្រះពុទ្ធ ទីលំនៅបច្ចុប្បន្នផ្ទះលេខ២០អឺ០ ក្រុមទី៦ ផ្លូវលេខ២០០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ ក្រុងភ្នំពេញ។ ឪពុកឈ្មោះ...ម្តាយឈ្មោះ...នៅលីវ ដាក់ពន្ធនាគារកំណត់១០ឆ្នាំ គិតពីថ្ងៃឃុំខ្លួន ពីបទសម្លាប់មនុស្សគិតទុកជាមុន និងប្លន់ បទល្មើស ដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣១,៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៦-០៨-១៩៩៦។

២-ឱ្យឈ្មោះ **ឃសធ** សងទ្រព្យសម្បត្តិដែលបាត់បង់សរុបជាទឹកប្រាក់ ២៤.៣០០ដុល្លាអាមេរិក និងជំងឺចិត្ត០១ម៉ឺនដុល្លាអាមេរិក ទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ **គហ** សំណូមពរលើសពីនេះបដិសេធចោល។ បើជននេះរឹងរូបមិនព្រមសង ត្រូវដាក់គុកបង្ខំដល់រូបកាយ ដើម្បីទារប្រាក់ធនទណ្ឌ តាមច្បាប់ស្ដីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ។

៣-វត្ថុតាងមាន៖

-រថយន្តម៉ាកតូយូតាស្រ្ដីនធ័រពណ៌ស១គ្រឿង

-ម៉ូតូរ៉ូឡាលេខ៨៨០០ អ៊ឹច ០១គ្រឿង

-នាឡិកាដៃម៉ាក ហ្គោលស្ដារប្រើថ្ម១គ្រឿង

-ចិញ្ចៀនធ្វើពីលោហធាតុ ពណ៌លឿង និងទង់ដែង៣វង់ត្រូវរឹបអូសដើម្បីធានាសំណង់។

-អាវុធខ្លីធុនកា៥៩ គ្មានលេខ០១ដើម

-ម្ជុកថ្នាក់វរៈសេនីយ៍០២

-សក្តិថ្នាក់វរៈសេនីយ៍០១ ត្រូវប្រគល់ឱ្យឈ្មោះ **ឃសធ** វិញ

-ក្រម៉ា០២

-ក្រណាត់ស្រោមពួកប្រឡាក់ឈាម០១ ត្រូវរឹបអូសបំផ្លាញចោល។

៤-សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

- បានឃើញ បណ្តឹងឧទ្ធរណ៍លេខ៧១(ខ)ចុះថ្ងៃទី០៤-១១-១៩៩៧ របស់ឈ្មោះ **គហ** ប្ដឹងមិនសុខចិត្តពីសាលក្រមព្រហ្មទណ្ឌលេខ៧១(ខ)ចុះថ្ងៃទី០៤-១១-១៩៩៧ របស់តុលាការក្រុងភ្នំពេញត្រង់ចំណុចទី២ អំពីសំណងជំងឺចិត្ត។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ៣៨(ខ)ចុះថ្ងៃទី២៥-១១-១៩៩៧ របស់មេធាវីការពារឱ្យជនជាប់ចោទ ប្តឹងមិនសុខចិត្ត ពីសាលក្រមព្រហ្មទណ្ឌលេខ៧១(ខ) ចុះថ្ងៃទី៤-១១-៩៧ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសម្រេចទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ថា៖

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៥-១១១៩៩៧ របស់លោកមេធាវី... ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខុសនិងគតិច្បាប់។

២-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១១-១១-១៩៩៧ របស់ឈ្មោះ **គហ** ជាដើមបណ្តឹងទុកជាត្រឹមត្រូវតាមទម្រង់ នឹងគតិច្បាប់។

៣-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ៧១(ខ) ចុះថ្ងៃទី០៤-១១-១៩៩៧ ទុកជាបានការពេញទាំងមូល។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១៦៤ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារ សេចក្តីសម្រេចដូចតទៅ៖

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១១-១១-១៩៩៧ របស់ឈ្មោះ **គហ** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយទាស់ នឹងគតិច្បាប់។

២-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៥-១១-១៩៩៧ របស់មេធាវីលោក...ជាមេធាវីរបស់ ឈ្មោះ **ឃសធ** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយទាស់នឹងគតិច្បាប់។

៣-តម្កល់សាលក្រមទណ្ឌលេខ៧១(ខ)ចុះថ្ងៃទី០៤-១១-១៩៩៧ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ដោយគ្រាន់តែលុបមាត្រា៣៤ នៃ

ច្បាប់ព្រហ្មទណ្ឌអន្តរកាលក្នុងចំណុចទី១ នៃសេចក្តីសម្រេចចោល។ ចំណុចក្រៅពីនេះ តម្កល់ទុកជាបានការដដែល។

៤-សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ បើកផ្លូវប្តឹងទាស់ និងសាទុក្ខតាមកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ៥៨ ចុះថ្ងៃទី០១-៧-១៩៩៩ របស់លោកមេធាវី... មេធាវីការពារឱ្យជនជាប់ចោទ ប្តឹងមិនសុខចិត្ត ពីសាលដីកាព្រហ្មទណ្ឌលេខ១៦៤ ចុះថ្ងៃទី២៥-៦-១៩៩៩របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល ។

-បានឃើញសារណារបស់ មេធាវីការពារឱ្យជនជាប់ចោទឈ្មោះ **ឃសធ** ចុះថ្ងៃទី១៩-១០-១៩៩៩ ធ្វើឡើងតាមកំណត់ច្បាប់។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមតុលាការកំពូលថា៖

១-មានពិរុទ្ធភាព និងភស្តុតាងគ្រប់គ្រាន់លើឈ្មោះ **ឃសធ** ពីបទមនុស្សឃាតដោយចេតនាគិតទុកជាមុន ពិតប្រាកដមែន។

៦-តម្កល់សាលដីកាបស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល។

-បានស្តាប់សារណារបស់ជនជាប់ចោទឈ្មោះ **ឃសធ**

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមេធាវី...ការពារឱ្យជនជាប់ចោទថា៖ ឆ្លងតាមសារណារបស់ខ្ញុំ បញ្ជាក់ឱ្យឃើញថា៖ តាមចម្លើយសាក្សីខ្លះថាជនជាប់ចោទមានគ្នា៥នាក់ ឯសាក្សីខ្លះទៀតថា មានគ្នា៣នាក់ ហេតុនេះតុលាការមិនអាចយកជាការបានទេ។ តាមចម្លើយសាក្សីឃើញហេតុការនិយាយថា ឃើញ

មនុស្សម្នាក់ទៀតឆ្លើយថា បានឮជនជាប់ចោទគំរាមថា កុំមាត់ប្រយ័ត្នអាញ់សម្លាប់ចោល ហើយជនជាប់ចោទបានគំរាម **ឃសធ** ថាមិនឱ្យរាយការណ៍ប្រាប់ប៉ូលីសថា សម្លាប់ចោលមួយពូជ ដូច្នេះ **ឃសធ** ត្រូវបង្ខំចិត្តពុំរាយការណ៍ប្រាប់ប៉ូលីល ដើម្បីការពារសុវត្ថិភាពក្រុមគ្រួសាររបស់ខ្លួន។

គ្រួសាររបស់ខ្លួន សំណូមពរតុលាការកំពូលបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ ហើយសូមឱ្យកូនក្តីខ្ញុំបាទរួចផុតពីការចោទប្រកាន់។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការថា៖ ការលើកឡើងរបស់លោកមេធាវី គឺគ្មានភស្តុតាងផ្ទុយតុលាការសម្រេចតាមច្បាប់ចុះ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណារបស់ជនជាប់ចោទ និង សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវ តាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថាបណ្តឹងសាទុក្ខលេខ៥៨៨ចុះថ្ងៃទី០១-០៧-១៩៩៩ របស់លោក...មេធាវីការពារជនជាប់ចោទ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី។

-យល់ឃើញថា ការដែលឈ្មោះ **ឃសធ** ក៏ដូចជាមេធាវីដែរ ដែលលើកឡើងក្នុងសារណា ចុះថ្ងៃទី១៩-១០-១៩៩៩ ថាជនជាប់ចោទឈ្មោះ **ឃសធ**ធ្វើសកម្មភាពក្នុងអំពើល្មើស ដោយសារតែមានការគំរាមកំហែងពីឈ្មោះ **រ** និង

បក្សពួករបស់ឈ្មោះ **វ** នោះតុលាការកំពូល ពុំអាចពិចារណាបានឡើយ ដោយហេតុថាក្រោយពីឈ្មោះ **ឃសធ** ចុះពីរថយន្ត នៅកន្លែងលើកអាល់ទៃក្បែរសង្កាត់បឹងរាំងនោះមកឈ្មោះនេះលែងមានការគំរាមកំហែងទៀតហើយ ប៉ុន្តែឈ្មោះនេះនៅតែព្យាយាមបន្តយករថយន្ត ទៅឱ្យឈ្មោះ **វ** នៅព្រែកឯងម្តងជាពីរដង មិនបានជួប ហើយរហូតដល់បើកឡានតាមមនុស្សជិះម៉ូតូនាំមុខឱ្យទៅជួបឈ្មោះ **វ** រួចខ្លួនបានប្រគល់សោរឡានឱ្យទៅឈ្មោះ **វ** នៅម្តុំអាងទឹកអូឡាំពិកទៀតផងហើយខ្លួនព្យាយាមគេចខ្លួនរហូតទាល់តែសមត្ថកិច្ចស្រាវជ្រាវរកឃើញនិងចាប់ខ្លួនបាន។ ម្យ៉ាងទៀតជនជាប់ចោទ និងមេធាវីរបស់ខ្លួនពុំមានភស្តុតាងបញ្ជាក់ថាពិតជាមានការគំរាមកំហែងទេ។

-យល់ឃើញថាឈ្មោះ **ឃសធ** មានតួនាទីជានគរបាល ពិតជាដឹងច្បាស់លាស់ពីសមត្ថកិច្ចដោះស្រាយ ហើយខ្លួន ស្នាក់នៅជិតអធិការដ្ឋាននគរបាលខណ្ឌដូនពេញស្រាប់ ប៉ុន្តែបែរជាយកលេសថា ខ្លួនបានទៅរាយការណ៍ពីហេតុការណ៍នេះជូនអង្គភាពធ្វើការរួចហើយម្យ៉ាងទៀតលិខិតបញ្ជាក់លេខ០៨៤ព្រទ ចុះថ្ងៃទី៣១-៧-១៩៩៨ របស់លោក **អបរ** ប្រធាននាយកដ្ឋាននគរបាលព្រហ្មទណ្ឌ នៃក្រសួងមហាផ្ទៃដែលបញ្ជាក់ថា ឈ្មោះ **ឃសធ** បានមករាយការណ៍ផ្ទាល់មាត់ដែរ ក៏ទើបធ្វើនៅថ្ងៃទី៣១-៧-១៩៩៨ គឺក្រោយថ្ងៃកើតហេតុអស់រយៈពេលជិតពីរឆ្នាំហើយ។ ដូច្នេះ តុលាការកំពូល ពុំអាចលើកយកលិខិតនេះមកធ្វើជាភស្តុតាងដោះបន្ទុកឱ្យជនជាប់ចោទបានឡើយ។

-យល់ឃើញថា ជនជាប់ចោទបានធ្វើសារណាការពាររឿងក្តីរបស់ខ្លួនរួចហើយ ប៉ុន្តែពុំបានមកចូលរួមទាពេលសវនាការនេះទេ មានតែមេធាវីរបស់ជនជាប់ចោទដូច្នេះ តុលាការកំពូលជំនុំជម្រះកំបាំងមុខចាត់ទុកជាចំពោះមុខ។

-យល់ឃើញថា ដើមបណ្ដឹងរដ្ឋប្បវេណី ពុំបានធ្វើសារណាការពាររឿងក្ដីរបស់ខ្លួនទេ ហើយក៏ពុំបានមក ចូលរួមនាពេលសវនាការនេះដែរ ដូច្នេះតុលាការកំពូលជំនុំជម្រះរឿងនេះ កំបាំងមុខចាត់ទុកជាចំពោះមុខ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ១៦៤ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្ដីមកនេះ មានក្ខណៈត្រឹមត្រូវទាំងទម្រង់ទាំងគតិច្បាប់ហើយ។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្ដីកំបាំងមុខជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ

១-ទទួលបណ្ដឹងសាទុក្ខលេខ៥៨ ចុះថ្ងៃទី០១-៧-១៩៩៩ របស់លោក ...មេធាវីការពារឱ្យជនជាប់ចោទឈ្មោះ **ឃសធ** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់ខុសនឹងគតិច្បាប់។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ១៦៤ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ ១៩៤៩ របស់សាលាឧទ្ធរណ៍ទុកជាបាន ការពេញទាំងមូល។

៣-សាលដីកានេះប្រកាសជាសាធារណៈ នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ ២០០០។